# ពួក 12 នាក់

ប្រធានបិយឃេ ផាកកឺ
ប្រធាននៃក្រុមសាវ័ក 12 នាក់

*ត្បិតសាសនាចក្រជាសាសនាចក្ររបស់ទ្រង់ នោះត្រូវតែមានក្រុមនៃពួក 12 នាក់ ដែលកាន់កូនសោទាំងឡាយ ។*

មិនយូរប៉ុន្មានបន្ទាប់ពីមរណភាពរបស់ប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី ជាបុរសទីដប់បួន ពួកសាវ័ក ដែលបានប្រទាន ដល់ពួកគេនូវកូនសោទាំងឡាយនៃនគរ បានប្រមូលផ្តុំគ្នានៅក្នុងបន្ទប់ខាងលើនៃព្រះវិហារបរិសុទ្ធ ដើម្បីតែងតាំង គណៈប្រធានទីមួយនៃសាសនាចក្រ ។ អ្វីដែលបានធ្វើឡើងគឺគ្មានសំណួរ និងការស្ទាក់ស្ទើរនោះទេ។ យើងដឹង ថាសាវ័ក រៀមច្បង គឺជាប្រធាននៃសាសនាចក្រ។ ហើយនៅក្នុងការប្រជុំដ៏ពិសិដ្ឋនោះ លោកថូម៉ាស អេស ម៉នសុន ត្រូវបាន គាំទ្រដោយក្រុមនៃពួក 12 នាក់ ធ្វើជាប្រធាននៃសាសនាចក្រ ។ លោកបានតែងតាំង និងបានហៅឈ្មោះទីប្រឹក្សារបស់ លោក។ ពួកលោកក៏ត្រូវបានតែងតាំងផងដែរ ហើយពួកលោកម្នាក់ៗត្រូវបានតែងតាំង និងប្រគល់សិទ្ធិអំណាចឱ្យ។ ប្រធាន ម៉នសុន ជាពិសេសត្រូវបានប្រគល់ឱ្យនូវសិទ្ធិអំណាច ដើម្បីអនុវត្តនូវសិទ្ធិអំណាចនៃកូនសោទាំងអស់ នៃបព្វជិតភាព។ ឥឡូវនេះ ដូចដែលបទគម្ពីរបានផ្តល់ឱ្យ លោកគឺជាបុរសតែម្នាក់នៅលើផែនដី ដែលមានសិទ្ធិដើម្បីអនុវត្តនូវកូនសោទាំង អស់ ។ ប៉ុន្តែយើងទាំងអស់គ្នាកាន់កូនសោទាំងអស់នោះក្នុងនាមជាពួកសាវ័ក។ មានបុរសម្នាក់នៅក្នុងចំណោមយើងបានហៅ និងតែងតាំង ហើយលោកបានក្លាយទៅជាប្រធាននៃសាសនាចក្រនៃ ព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ។ លោកត្រូវបាន និងបានតែងតាំងអស់ជាច្រើនឆ្នាំរួចមកហើយ ក្នុងនាមជាព្យាការី អ្នកមើលឆុត និងអ្នកទទួលវិវរណៈ ។

ព្រមជាមួយនឹងប្រធាន អុជដូហ្វ ត្រូវបានហៅមកកាន់គណៈប្រធានទីមួយ ដែលពីមុនជាបេក្ខជននៅក្នុងពួក 12 នាក់ កាលពីម្សិលមិញនេះយើងបានតែងតាំងសមាជិកថ្មីមួយរូប នៃក្រុម នៃពួក 12 នាក់ គឺអែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន ។ ឥឡូវលោកចូលរួមនៅក្នុងភាពជាបងប្អូនប្រុសដ៏ពិសិដ្ឋ នៅក្នុងរង្វង់ដ៏ពិសិដ្ឋនោះ ហើយក្នុងរង្វង់នោះបានបំពេញឱ្យមាន ពេញលេញហើយ ។ ការហៅសាវ័ក បានត្រឡប់ទៅកាន់ព្រះអម្ចាស់ ព្រះយេស៊ូវគ្រីស្ទ។

យើងក៏បានគាំទ្រសមាជិកមួយរូបនៃពួក 70 ផងដែរ។ ឥឡូវនេះ ពួកលោកបានអង្គុយនៅកន្លែងរបស់ ខ្លួនហើយ ។ បទគម្ពីរបានផ្តល់ឱ្យថា វាគឺជាការទទួលខុសត្រូវរបស់ក្រុម នៃពួកដប់ពីរនាក់ ដើម្បីដឹកនាំគ្រប់កិច្ចការទាំង អស់របស់សាសនាចក្រ ហើយនៅពេលពួកលោកត្រូវការជំនួយ នោះពួកលោក "ឱ្យស្នើដល់ពួក 70 នាក់... ជាជាងអ្នក ណាផ្សេងៗទៀត" ។ 1 ហើយឥឡូវនេះ យើងមានប្រាំបីក្រុមនៃពួក 70 នាក់ ដែលមាននៅពាសពេញពិភពលោក ពួក 70 នាក់មានច្រើនជាង 300 នាក់ ទាំងអស់មានសិទ្ធិអំណាចសំខាន់ៗដើម្បីធ្វើអ្វី ដែលពួក 12 នាក់ដឹកនាំពួកលោក ឱ្យធ្វើ ។

ព្រះអម្ចាស់ផ្ទាល់ បានដាក់គំរូនៃការគ្រប់គ្រងនេះ:

"ទ្រង់ចេញទៅឯភ្នំ ដើម្បីនឹងអធិស្ឋាន រួចទ្រង់អធិស្ឋានដល់ព្រះ ដរាបទាល់ភ្លឺ" ។

"លុះភ្លឺឡើងទ្រង់ហៅពួកសិស្សមកៈ ក៏រើសយក 12 នាក់ ដែលទ្រង់ហៅថា សាវ័ក" ។2

អនទ្រេ បានឮយ៉ូហាននិយាយ ហើយបានរត់ទៅកាន់បងប្រុសរបស់គាត់ ស៊ីម៉ូន ហើយនិយាយថា

"យើងបានឃើញព្រះមែស៊ីហើយ..."។

"...រួចគាត់នាំបងទៅឯព្រះយេស៊ូវ ឯទ្រង់ក៏ទតមើលគាត់ ហើយមានបន្ទូលថា អ្នកឈ្មោះស៊ីម៉ូន ជាកូនយ៉ូណាសៈ តែត្រូវហៅថា កេផាសវិញ គឺប្រែថាថ្ម"។3

ស៊ីម៉ូន និងប្អូនប្រុសរបស់គាត់ អនទ្រេ កំពុងតែបោះអួនទៅក្នុងសមុទ្រ យ៉ាកុប និងយ៉ូហាន ជាកូនសេបេដេ កំពុងតែជួសអួន លោកភីលីព លោកបារថូលូមេ លោកថូម៉ាស លោកម៉ាថាយ ជាអ្នកយកពន្ធម្នាក់ លោកយ៉ាកុប ជាកូនអាលផាយ លោកស៊ីម៉ូន ជាសាសន៍កាណាន ហើយនឹងយូដាស-អ៊ីស្ការីយ៉ុត--- ពួកគេដាក់បញ្ចូលជាក្រុម នៃក្រុមសាវកដប់ពីរនាក់។4

ទ្រង់បានមានបន្ទូលពួកគេទាំងអស់គ្នា ថា "ចូរមកតាមខ្ញុំចុះ"។5

ទ្រង់បានមានបន្ទូលទៅកាន់ ពេត្រុស ថា "ខ្ញុំនឹងឱ្យកូនសោរនៃនគរស្ថានសួគ៌ដល់អ្នក បើអ្នកនឹងចងទុកអ្វីៗ នៅផែនដី នោះនឹងត្រូវចងទុកនៅលើស្ថានសួគ៌ដែរ ហើយបើអ្នកនឹងស្រាយអ្វីៗនៅផែនដី នោះនឹងត្រូវស្រាយនៅ ស្ថានសួគ៌ដែរ"។6

ហើយទ្រង់បានប្រាប់ពួក 12 នាក់ថា "អ្នកណាដែលជឿដល់ខ្ញុំ នោះនឹងធ្វើការដែលខ្ញុំធ្វើដែរ ក៏នឹងធ្វើការធំជាង ការទាំងនោះទៅទៀត ពីព្រោះខ្ញុំទៅឯព្រះវរបិតា"។7

ទ្រង់បានប្រទានដល់ពួកសាវករបស់ទ្រង់នូវ "ព្រះចេស្តា និងអំណាចលើអស់ទាំងអារក្ស ហើយឱ្យអាចមើលជម្ងឺឱ្យ ជា។ ទ្រង់ចាត់គេឱ្យប្រកាសប្រាប់ពីនគរព្រះ ហើយឱ្យមើលមនុស្សមានជម្ងឺ...នៅគ្រប់កន្លែងដែរ "។8

ហើយទ្រង់បានមានបន្ទូលថា : "[ពួក] 12 នាក់ ដែលកាន់កូនសោទាំងឡាយ ដើម្បីបើកសិទ្ធិអំណាចនៃនគរ របស់យើង នៅលើជ្រុងទាំងបួននៃផែនដី ហើយបន្ទាប់ពីនោះឱ្យបញ្ជូនព្រះបន្ទូលរបស់យើងទៅដល់សត្វលោកគ្រប់រូប"។9

ព្រះយេស៊ូវបានសួរសិស្សរបស់ទ្រង់ថា "តើមនុស្សទាំងឡាយ គេថាកូនមនុស្សជាអ្នកណា?..."

" ស៊ីម៉ូន-ពេត្រុស ទូលឆ្លើយថា ទ្រង់ជាព្រះគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះដ៏មានព្រះជន្មរស់"។10

ពេលដែលព្រះយេស៊ូវបានបង្រៀននៅក្នុងសាលាប្រជុំ មានសិស្សជាច្រើនបាននិយាយថា "ពាក្យនេះពិបាកស្តាប់ណាស់ តើអ្នកណាយល់បាន?..."

"តាំងពីនោះមក មានសិស្សទ្រង់ជាច្រើនដកខ្លួនថយចេញ មិនតាមទ្រង់ទៀតទេ"។

"នោះព្រះយេស៊ូវមានបន្ទូលទៅពួក 12 នាក់ថា អ្នករាល់គ្នាចង់ថយទៅដែរឬ?"

"... ស៊ីម៉ូន-ពេត្រុសទូលឆ្លើយថា ព្រះអម្ចាស់អើយ តើយើងខ្ញុំនឹងទៅឯអ្នកណាវិញ គឺទ្រង់ហើយ ដែលមាន ព្រះបន្ទូលនៃជីវិតដ៏នៅអស់កល្បជានិច្ច"។11

ពួកសាវកបានចងចាំថា ក្រោយពីការឆ្កាង ទ្រង់មានបន្ទូលឱ្យពួកគេរស់នៅក្នុងយេរូសាឡិម។ 12 កាលបុណ្យ ថ្ងៃទី 50 បានមកដល់ រួចពួកគេបានពេញជាព្រះវិញ្ញាណបរិសុទ្ធទាំងអស់។ 13 ពួកគេបានទទួល "ពាក្យទំនាយដ៏ពិតជាង" 14 ហើយ "បានទាយដោយសារ ព្រះវិញ្ញាណបរិសុទ្ធទ្រង់បណ្តាលវិញ"។ 15 ហើយ ពួកគេត្រូវបានបំពេញយ៉ាង ដូច្នេះ។

យើងដឹងបន្តិចបន្តួចពីការធ្វើដំណើររបស់ពួកគេ និងទីកន្លែង និងរបៀបដែលពួកគេមួយចំនួនបានទទួល

មរណភាពតែប៉ុណ្ណោះ។ យ៉ាកុប ត្រូវបានគេសម្លាប់ នៅក្នុងយេរូសាឡិមដោយហេរ៉ូឌ។ ពេត្រុស និងប៉ុលបានទទួលមរណភាពនៅក្រុងរ៉ូម។ ប្រពៃណីថ្លែងថា ភីលីព បានធ្វើដំណើរទៅទិសខាងកើត។ រឿងរ៉ាវច្រើនជាងនេះយើងពុំបានដឹងឡើយ។

ពួកគេបានបែកខ្ញែក។ ពួកគេបានបង្រៀន និងបានធ្វើទីបន្ទាល់ បានស្ថាបនាសាសនាចក្រ។ ហើយពួកគេបានទទួមរណភាព ដើម្បីសេចក្ដីជំនឿរបស់ពួកគេ ហើយក្រោយពីមរណភាពរបស់ពួកគេ បាននាំមកនូវសតវត្សន៍ដ៏ខ្មៅងងឹតនៃការក្បត់សាសនា។

វត្ថុដ៏មានតម្លៃបំផុតបានបាត់បង់នៅក្នុងការក្បត់សាសនា គឺជាសិទ្ធិអំណាចដែលកាន់កាប់ដោយពួក 12 នាក់---ជាកូនសោបព្វជិតភាព។ ដើម្បីឱ្យសាសនាចក្រនេះ ក្លាយជា *សាសនាចក្ររបស់ទ្រង់* វាត្រូវតែមាននូវក្រុមសាវក 12 នាក់ ដែលកាន់កូនសោ និងផ្ដល់កូនសោរនោះទៅឱ្យអ្នកដទៃទៀត។

នៅទីបញ្ចប់ ទស្សនិមិត្តលើកដំបូង ហើយការស្ដារឡើងវិញនៃបព្វជិតភាពមិលគីស្សាដែក ដោយពេត្រុស យ៉ាកុប និងយ៉ូហានបានមកដល់។ 16

គណៈប្រធានទីមួយ និងក្រុម នៃពួកដប់ពីរនាក់ ក្រោយមកបានប្រាប់ថា:

"ត្បិតយើងប្រាប់អ្នកជាប្រាកដថា កូនសោទាំងឡាយនៃគ្រាកាន់ត្រួតត្រា ដែលអ្នករាល់គ្នាបានទទួល បានចុះមកពីពួកអយ្យកោ ហើយនៅចុងក្រោយបំផុត ត្រូវបានបញ្ជូនមកពីស្ថានសួគ៌ដល់អ្នក"។

"...មើលចុះ ការងាររបស់អ្នកធំណាស់ហ្ន៎!។ ចូរសំអាតចិត្តអ្នក និងសំលៀកបំពាក់អ្នកចុះ ក្រែងឈាមនៃតំណមនុស្សនេះតម្រូវពីដៃអ្នក"។ 17

សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ដែលបានស្ដារឡើងវិញ គឺនៅក្មេងខ្ចី ពេលដែលគណៈប្រធានទីមួយបានរៀបចំឡើង ក្រោយមកមាន ក្រុមនៃពួកសាវកដប់ពីរនាក់ ដែលត្រូវបានបង្កើតឡើងនៃពួកបុរសសាមញ្ញ ហើយរួចមកជាក្រុមនៃពួក 70 នាក់។ អាយុជាមធ្យមនៃក្រុមទីមួយនៃពួក 12 នាក់ គឺ 28 ឆ្នាំ។

ចាប់តាំងពីពេលនោះមកមាននូវតំណនៃសិទ្ធិអំណាចពេញលេញ។ កូនសោបព្វជិតភាពប្រទានឱ្យពួកសាវកជានិច្ចកាលត្រូវបានកាន់ដោយសមាជិកនៃគណៈប្រធានទីមួយ និង ក្រុមនៃក្រុមសាវកទាំង 12 នាក់។

កាលពីម្សិលមិញ អែលឌើរ ឌី ថត គ្រីស្ទហ្វឺសិន បានក្លាយជាសាវកទី 96 ដែលបំរើនៅក្នុងក្រុម 12 នាក់នៅគ្រាកាន់កាប់ត្រួតត្រានេះ។ លោកនឹងត្រូវបានតែងតាំងជាសាវក ហើយនឹងត្រូវបានផ្ដល់ឱ្យនូវកូនសោបព្វជិតភាពទាំងអស់មកលើពួកព្យាការី ពួកមើលឆុត និងពួកបើកសម្ដែង 14 រូបផ្សេងទៀត---ជាពួកសាវកនៃព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ---មាន។

នៅឆ្នាំ 1976 ផ្នែកមួយនៃសន្និសីទទូទៅ ត្រូវបានធ្វើឡើងនៅក្នុងខូផែនហាហ្គែន ប្រទេសដាណាម៉ាក។ បន្ទាប់ពីការបញ្ចប់សម័យប្រជុំ ប្រធានស្ពែនស៊ើរ ដបុលយូ឵ ឃីមប៊ល មានបំណងទៅទស្សនកិច្ច សាលាជំនុំវើរ ហ្វ្រូ ជាកន្លែងដែលរូបសំណាករបស់ព្រះគ្រីស្ទ និងសាវក 12 នាក់ ដែលធ្វើឡើងដោយលោក ធើរវ៉លសិនបានតាំងនៅ។ លោកបានទៅទស្សនកិច្ចនៅទីនោះកាលពីប៉ុន្មានឆ្នាំមុន និងចង់ឱ្យយើងទាំងអស់គ្នាមើលឃើញវា ហើយទៅទីនោះ។

នៅខាងក្រោយអសនៈ ដល់ខាងមុខព្រះវិហារ រូបសំណាកនៃព្រះគ្រីស្ទ ជាមួយនឹងព្រះហស្ដរបស់ទ្រង់

លាតសន្ធឹងទៅមុខស្រដៀងគ្នានេះដែរ ព្រះហស្តទាំងពីរនោះបង្ហាញនូវស្នាមដែកគោល និងរបួសនៅព្រះចំហៀងរបស់ទ្រង់បានលេចមកយ៉ាងច្បាស់។ នៅផ្នែកទាំងសងខាងមានរូបសំណាកនៃពួកសាវក ពេត្រុសនៅខាងមុខទៅខាងស្តាំ និងពួកសាវកដទៃទៀតជាលំដាប់លំដោយ។

ក្រុមរបស់យើងភាគច្រើន នៅក្បែរផ្នែកខាងក្រោយនៃសាលាជំនុំជាមួយអ្នកថែរក្សា។ ខ្ញុំបានក្រោកឈរនៅខាងមុខជាមួយនឹងប្រធាន ឃីមបឹល នៅខាងមុខរូបសំណាករបស់ពេត្រុស ជាមួយនឹងអែលឌើរ រ៉េក ឌី ភីនេហ្គើរ និង យ៉ូហាន់ ហែលហ្គ បែនស៊ីន ជាប្រធានស្តេក ខូផែនហាហ្គែន។

នៅក្នុងបាតដៃរបស់ពេត្រុស ដែលធ្វើឡើងពីថ្មកែវ គឺជាបណ្តុំនៃកូនសោធ្ងន់។ ប្រធាន ឃីមបឹល បានចង្អុលបង្ហាញទៅកូនសោនោះ ហើយពន្យល់នូវអ្វីដែលបានតំណាងឱ្យកូនសោនោះ។ បន្ទាប់មកក្នុងទង្វើរមួយដែលខ្ញុំមិនអាចបំភ្លេចបាន លោកបានមើលទៅប្រធាន បែនស៊ីន ជាមួយនឹងតរិយាបទដ៏ម៉ឺងម៉ាត់ បានចង្អុលទៅគាត់ ហើយនិយាយថា "ខ្ញុំចង់ឱ្យអ្នកប្រាប់មនុស្សគ្រប់គ្នានៅក្នុងប្រទេសដាណោម៉ាកថា ខ្ញុំកាន់នូវកូនសោនេះ! យើងកាន់កូនសោ*ពិត* ហើយយើងប្រើវាជារៀងរាល់ថ្ងៃ"។

ខ្ញុំមិនដែលភ្លេចឡើយនូវការប្រកាសនោះ ដែលជាទីបន្ទាល់មកពីព្យាការី។ ឥទ្ធិពលនោះមាននូវអនុភាពខាងវិញ្ញាណ ចំណាប់អារម្មណ៍គឺជាឥទ្ធិពលខាងវិញ្ញាណ។

យើងបានដើរទៅខាងក្រោយសាលាជំនុំ ដែលមានសមាជិកក្រុមដទៃទៀតកំពុងឈរនៅទីនោះ។ ដោយចង្អុលទៅរូបសំណាកនោះ ប្រធាន ឃីមបឹល បានមានប្រសាសន៍ទៅកាន់អ្នកថែទាំដ៏មានសណ្តានចិត្តថា "ទាំងនេះគឺជាពួកសាវកដែលបានទទួលមរណភាពទៅហើយ"។ លោកបានមានប្រសាសន៍ដោយចង្អុលមកខ្ញុំថា "យើងមានពួកសាវកដែល*នៅរស់* ។ អែលឌើរ ផាកកឺ ជាសាវក។ អែលឌើរ ថូម៉ាស អេស ម៉នសុន និងអែលឌើរ អិល ថម ភែរី ជាសាវក ហើយរូបខ្ញុំជាសាវក។ យើងគឺជាពួកសាវកដែលនៅរស់។

"អ្នកបានអានអំពីពួក 70 នាក់ នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ហើយនៅទីនេះមានពួក 70 នាក់ដែលរស់ពីររូប អែលឌើរ រ៉េក ឌី ភីនេហ្គើរ និងអែលឌើរ រ៉ូបឺត ឌី ហែល "។

អ្នកថែទាំ មកដល់ពេលនោះមិនបានបង្ហាញនូវអារម្មណ៍ណាមួយឡើយ តែមួយរំពេចក្រោយពួកគេបានស្រក់ទឹកភ្នែក។

ខ្ញុំមានអារម្មណ៍ថា ខ្ញុំមាននូវបទពិសោធន៍ដ៏ពិសេសបំផុត។

"យើងខ្ញុំជឿចំពោះការរៀបចំដូចគ្នា ដូចដែលនៅក្នុងសាសនាចក្រពីអតីតកាល ដូចជាពួកសាវក ពួកព្យាការី ពួកគ្រូ គង្វាល ពួកគ្រូ ពួកគ្រូផ្សាយដំណឹងល្អជាដើម"។18

ពេលដែលពួក 70 នាក់ត្រូវបានគេតែងតាំង ទោះបីជាយ៉ាងណាក៏ដោយ ពួកគេមិនត្រូវបានតែងតាំងទេ។ ពួកសាវកមិនទាំងកាន់កូនសោឡើយ ហើយពួក 12 នាក់ "ស្មើដល់ពួក 70 នាក់ កាលណាពួកគេត្រូវការជំនួយ ដើម្បីបំពេញការងារនានាខាងការផ្សាយ និងការចាត់ចែងដំណឹងល្អជាជាងអ្នកណាផ្សេងៗទៀត"។19

សព្វថ្ងៃនេះ មានពួក 70 នាក់ចំនួន 308 រូប ចែកជា 8 ក្រុម។ ពួកគេតំណាងឱ្យ 44 ប្រទេស និងនិយាយ 30ភាសា។

យើងពុំបានឮពីកូនសោបព្វជិតភាពត្រូវបានគេអនុវត្តនៅក្នុងព្រះវិហារគ្រីស្ទានដទៃទៀតឡើយ ។ វាគួរឱ្យចម្លែកដែលយើងត្រូវបានរៀបរាប់ដោយបុគ្គលខ្លះថាមិនមែនជាគ្រីស្ទាន ពេលដែលយើងគឺជាសាសនាចក្រតែមួយគត់ដែលមានសិទ្ធិអំណាច និងការរៀបចំដែលព្រះគ្រីស្ទបានស្ថាបនាឡើង ។

ពួក 12 នាក់នាបច្ចុប្បន្ននេះ គឺជាមនុស្សសាមញ្ញបំផុត ។ ពួកគាត់មិនមែនជាមនុស្សអស្ចារ្យ ក៏ដូចជាពួក 12 នាក់ ជំនាន់ដើមផងដែរ ប៉ុន្តែដោយរួមចូលគ្នា ពួក 12 នាក់គឺជាក្រុមមួយដែលមានអំណាចដ៏អស្ចារ្យ ។

យើងជាពួកសាវកមកពីអាជីពការងារខុសគ្នា ។ ពួកយើងជា អ្នកវិទ្យាសាស្ត្រ មេធាវី និងជាគ្រូបង្រៀន ។

អែលឌើរនែលសុន គឺជាពេទ្យវះកាត់បេះដូងដែលបានណែនាំនូវនីតិវិធីថ្មី ។ លោកបានអនុវត្តការវះកាត់មនុស្សរាប់ពាន់ ។ លោកបានប្រាប់ខ្ញុំថា លោកបានផ្តល់ដល់អ្នកជម្ងឺដែលវះកាត់បេះដូងគ្រប់រូបនូវការធានាអះអាង នៅក្នុងកិច្ចការរបស់លោកអស់មួយជីវិត ។

មានមនុស្សមួយចំនួននៅក្នុងក្រុមនេះបានចូលបំរើនៅក្នុងកងទ័ព---ជាពលទាហានជើងទឹក ជាទ័ពជើងទឹក ជាអ្នកបើកយន្តហោះ ។

ពួកគាត់មានតួនាទីនៅក្នុងខុសៗគ្នា នៅក្នុងសាសនាចក្រៈជាគ្រូបង្រៀនតាមផ្ទះ អ្នកណែនាំ អ្នកផ្សព្វផ្សាយសាសនា ប្រធានក្រុម ប៊ីស្សព ប្រធានស្តេក ប្រធានបេសកកម្ម ហើយតួនាទីដ៏សំខាន់បំផុត គឺជាស្វាមី និងឪពុក ។

ពួកគាត់ទាំងអស់គ្នា ជាសិស្ស និងជាគ្រូបង្រៀននៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។ អ្វីដែលចងភ្ជាប់យើងបញ្ចូលគ្នា គឺជាសេចក្តីស្រឡាញ់នៃព្រះអង្គសង្គ្រោះ និងកូនចៅរបស់ព្រះវរបិតារបស់ទ្រង់ និងទីបន្ទាល់របស់យើងដែលថាទ្រង់គង់ជាអ្នកដឹកនាំនៃសាសនាចក្រ ។

ពួក 12 នាក់ស្ទើរតែទាំងអស់ចេញពីការចាប់ផ្តើមដ៏រាបសារ ដូចនៅពេលដែលព្រះគ្រីស្ទគង់នៅទីនេះ ។ ពួក 12 នាក់ដែលនៅរស់ បានរួបរួមគ្នានៅក្នុងការបំរើដល់ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។ ពេលដែលការហៅបានមកដល់ពួកគាត់ម្នាក់ៗបានទុកសំណាញ់ចោល ហើយទៅតាមព្រះអម្ចាស់ភ្លាម ។

ប្រធាន ឃីម ត្រូវបានគេរំឭកចាំដោយសារការថ្លែងរបស់លោកថាៈ "ឆាកជីវិតរបស់ខ្ញុំប្រៀបបាននឹងស្បែកជើងរបស់ខ្ញុំ---ដើម្បីពាក់នៅក្នុងការបំរើ" ។ 20 ការណ៍នោះអនុវត្តចំពោះសមាជិកនៃពួក 12 នាក់ទាំងអស់ ។ យើងក៏ពាក់ខ្លួនឯងក្នុងការបំរើនៃព្រះអម្ចាស់ដែរ ហើយយើងធ្វើបែបនេះដោយស្ម័គ្រចិត្ត ។ វាពុំមែនជាជីវិតដ៏ងាយស្រួលសំរាប់យើង និងក្រុមគ្រួសាររបស់យើងឡើយ ។

វាគ្មានពាក្យដើម្បីនឹងពិពណ៌នានូវការបរិច្ចាគ ការបំរើ ការពលិកម្មដែលបានផ្តល់ឱ្យដោយភរិយា នៃពួកអ្នកដឹកនាំបព្វជិតភាពទូទាំងពិភពលោកទាំងអស់បានទេ ។

ប៉ុន្មានឆ្នាំមុន ភរិយារបស់ខ្ញុំ ព្រមទាំងស៊ិស្ទើរ បាឡឺដ ផងដែរ បានទទួលនូវការវះកាត់ខ្នងដ៏ឈឺចាប់បំផុត ។ ពួកគាត់ទាំងពីរនាក់ បានប្រសើរឡើងហើយ គ្មាននរណាម្នាក់បានរអូរទាំឡើយ ។ ការត្អូញត្អែរតូចមួយដែលភរិយារបស់ខ្ញុំមានគឺ "នេះមិនជារឿងសប្បាយសោះ!"

វា "គឺជាភារកិច្ចរបស់ពួក 12 នាក់"---នៅក្រោមការដឹកនាំនៃគណៈប្រធានទីមួយ---ដើម្បី "តែងតាំង ហើយ រៀបចំអស់ទាំងពួកអ្នកកាន់តំណែងផ្សេងៗទៀតនៅក្នុងសាសនាចក្រ ឱ្យមានរបៀបរៀបរយយល់

ព្រមតាមវិវរណៈ" ។21

ឥឡូវនេះ យើងមានមធ្យោបាយដែលអាចបង្រៀន និងធ្វើទីបន្ទាល់ចំពោះពួកអ្នកដឹកនាំនិងសមាជិកទាំងឡាយនៅជុំវិញពិភពលោកតាមអេឡិចត្រូនិច។ ប៉ុន្តែដើម្បីផ្ដល់កូនសោនៃសិទ្ធិអំណាចនៅក្នុងតំណរដ៏ពេញលេញនោះ ចំពោះពួកអ្នកដឹកនាំបព្វជិតភាព "ដោយការដាក់ដៃលើ" 22 ទោះបីពួកអ្នកដឹកនាំបព្វជិតភាពនៅទីណានៃពិភពលោកក៏ដោយ បុគ្គលម្នាក់ក្នុងចំណោមពួកយើងត្រូវតែមានវត្តមាននៅទីនោះគ្រប់ពេលវេលា។

ព្រះអម្ចាស់មានបន្ទូលថា "ហើយជាថ្មីទៀត យើងប្រាប់អ្នកថា នរណាក៏ដោយដែលអ្នករាល់គ្នានឹងចាត់ឱ្យទៅ ដោយនូវព្រះនាមរបស់យើង ដោយសម្លេងនៃពួកបងប្អូនរបស់អ្នកក្នុងសាសនា គឺពួក 12 នាក់ គឺបានរ៉ាប់រង និងអនុញ្ញាតដោយអ្នកពេញច្បាប់ នោះនឹងមានអំណាចដើម្បីបើកទ្វារនគររបស់យើងដល់សាសន៍ណាមួយក៏ដោយ ដែលអ្នករាល់គ្នានឹងចាត់ឱ្យពួកគេទៅ" ។23

បទគម្ពីរទាំងឡាយបានរៀបរាប់ពីពួក 12 នាក់ជា "ពួកអ្នកប្រឹក្សាដែលធ្វើដំណើរ" ។24

ខ្ញុំគ្មានអ្វីខុសប្លែកពីបងប្អូនប្រុសនៃពួក 12 នាក់ និងពួក 70 នាក់ និងគណៈប៊ីស្សពឡើយ ជាអ្នកដែលខ្ញុំបានបំរើការជាមួយអស់រយៈពេល 47 ឆ្នាំ ពេលដែលខ្ញុំប្រាប់អ្នកនូវឯកសារដែលបង្ហាញថា ខ្ញុំធ្លាប់ទៅប្រទេសម៉ិកស៊ិកូ ព្រមទាំងអាមេរិកកណ្ដាល និងអាមេរិកខាងត្បូងច្រើនជាង 75 លើក ទៅអឺរ៉ុបជាង 50 លើក ប្រទេសកាណាដា 25 លើក កោះប៉ាស៊ិភិច 10 លើក អាស៊ី 10 លើក និងប្រទេសអាហ្វ្រិកចំនួន 4 លើក រួមទាំងប្រទេសចិន 2 លើក ទៅប្រទេសអ៊ីស្រាអែល ប្រទេសអារ៉ាប៊ី សាអូឌី ប្រទេសបាហរាន ប្រទេសសាធារណរដ្ឋ ដូមីនីកែន ប្រទេសឥណ្ឌា ប្រទេសប៉ាគីស្ថាន ប្រទេសអេស៊ីព្ទ ប្រទេសឥណ្ឌូណេស៊ី និងជាច្រើនកន្លែងទៀតជុំវិញពិភពលោក។ អ្នកដទៃ បានធ្វើដំណើរកាន់តែច្រើនជាងនោះ។

ខណៈដែលពួកសាវកកាន់កូនសោបព្វជិតភាពទាំងអស់ រាល់ពួកអ្នកដឹកនាំ និងសមាជិកទាំងឡាយក៏ ដូចគ្នាដែរ អាចទទួលនូវវិវរណៈផ្ទាល់ខ្លួន។ ជាងនេះទៅទៀត ពួកគេត្រូវបានរំពឹងទុកដើម្បីស្វែងរកនូវវិវរណៈនោះ តាមរយៈការអធិស្ឋាន ហើយធ្វើតាមវាដោយសេចក្ដីជំនឿ។

"ត្បិតដោយសារទ្រង់នោះយើង...មានផ្លូវចូលទៅដល់ព្រះវរបិតាដោយព្រះវិញ្ញាណបរិសុទ្ធតែមួយ"

"ដូច្នេះអ្នករាល់គ្នាមិនមែនជាអ្នកដទៃ ឬជាអ្នកគ្រាន់តែសំណាក់នៅទៀតទេ គឺជាជាតិតែមួយនឹងពួកបរិសុទ្ធ ជាពួកដំណាក់ព្រះវិញ"

"ដែលបានស្អាងឡើងលើជើងជញ្ជាំងនៃពួកសាវក និងពួកហោរា ហើយព្រះយេស៊ូវគ្រីស្ទនោះឯង ទ្រង់ជាថ្មជ្រុងយ៉ាងឯក" ។25

ឥឡូវនេះ អែលឌើរ គ្រីស្ទហ្វឺសិន អាចឆ្ងល់ ដូចជាខ្ញុំផងដែរ ថាហេតុអ្វីបានជាបុគ្គលដូចជារូបខ្ញុំគប្បីត្រូវបានតែងតាំងឱ្យមានភាពជាសាវកបរិសុទ្ធ។

មាននូវគុណសម្បត្តិជាច្រើនដែលខ្ញុំខ្វះខាត។ មាននូវការខិតខំដើម្បីបំរើជាច្រើនរបស់ខ្ញុំ ដែលមានការខ្វះខាត។ មានតែរឿងមួយគត់ គុណសម្បត្តិមួយគត់ដែលអាចពន្យល់សំណួរនេះបាន។ ដូចជាពេត្រុស និងអ្នកទាំងអស់ណាដែលត្រូវបានតែងតាំងចាប់តាំងពីដំបូងមកថា ខ្ញុំមាននូវទីបន្ទាល់នៃទេវភាពរបស់ព្រះយេស៊ូវគ្រីស្ទ។

ខ្ញុំដឹងថាព្រះគឺជាព្រះវរបិតារបស់យើង។ ទ្រង់បានណែនាំព្រះរាជបុត្រារបស់ទ្រង់ដល់ យ៉ូសែប ស្ម៊ីធ។ ខ្ញុំសូមប្រកាសដល់អ្នករាល់គ្នាថា ខ្ញុំដឹងថាព្រះយេស៊ូវ គឺជាព្រះគ្រីស្ទ។ ខ្ញុំដឹងថាទ្រង់មានព្រះជន្មរស់។ ទ្រង់បានប្រសូត្រនៅក្នុងកាលលដ៏ខ្ពង់ខ្ពស់បំផុត។ ទ្រង់បានបង្រៀនដំណឹងល្អរបស់ទ្រង់ ហើយបានពិសោធនឹងការសាកល្បង។ ទ្រង់បានរងទុក្ខ ហើយត្រូវបានគេឆ្កាង ហើយបានរស់ឡើងវិញនៅថ្ងៃទីបី។ ទ្រង់ ដូចជាព្រះវរបិតាទ្រង់ មានព្រះកាយជាសាច់ និងឆ្អឹង។ ទ្រង់បានសំរេចនូវដង្វាយធួនរបស់ទ្រង់។ ខ្ញុំថ្លែងជាសាក្សីអំពីទ្រង់។ ខ្ញុំធ្វើជាសាក្សីអំពីទ្រង់។ ការណ៍នេះខ្ញុំថ្លែងក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន។

កំណត់ចំណាំ

1. គ. និង ស. 107: 38 ។
2. លូកា 6:12--13 ។
3. យ៉ូហាន 1:41--42 ។
4. សូមមើលលូកា 6: 12--16 ។
5. សូមមើលម៉ាថាយ 4: 19, 16:24 ម៉ាកុស 6:1 លូកា 9:23 សូមមើលយ៉ូហាន 21: 19 គ. និង ស. 112: 14 ។
6. ម៉ាថាយ 16:19 ។
7. យ៉ូហាន 14: 12 ។
8. លូកា 9:1--2, 6 ។
9. គ. និង ស. 124:128 ។
10. ម៉ាថាយ 16:13, 16 ។
11. យ៉ូហាន 6:60, 66--68 ។
12. សូមមើលកិច្ចការ 1:4 ។
13. សូមមើលកិច្ចការ 2:1--4 ។
14. ពេត្រុសទី 2 1:19 ។
15. ពេត្រុសទី 2 1:21 ។
16. សូមមើល គ. និង ស. 27:12 យ៉ូសែប ស្ម៊ីធ--- ប្រវត្តិ 1:72 ។
17. គ. និងស. 112: 32--33 ។
18. មាត្រានៃសេចក្តីជំនឿ 1:5 ។
19. គ. និង ស. 107:38 ។
20. នៅក្នុង ហ្គរដុន ប៊ី ហ៊ិងគ្លី "The Gift of Self," *Tambuli* ខែ ធ្នូ ឆ្នាំ 1986, 4; " He Is at Peace, " *Ensign,* ខែ ធ្នូ ឆ្នាំ 1985, 41 ។
21. គ. និង ស. 107: 58 សូមមើល គ. និង ស. 107: 33 ។

22. មាត្រានៃសេចក្ដីជំនឿ 1:5 ។

23. គ. និង ស. 112:21 ។

24. គ. និង ស. 107:23 ។

25. អេភេសូ 2:18--20 ។